# *X-Plain™*
# ជម្ងឺមហារីកដោះ
# ឯកសារយោង

គ្រោះថ្នាក់នៃជម្ងឺមហារីកក្នុងចំណោមជនជាតិអាស៊ីអាមេរិកាំងដែលរស់នៅក្នុងសហរដ្ឋអាមេរិក គឺមានតិច បើប្រៀបធៀបទៅនឹងស្ត្រីជនជាតិស្បែកស ។ ទោះជាយ៉ាងនេះក្តី យើងក៏មានការបារម្ភព្រោះថាគ្រោះថ្នាក់នៃជម្ងឺមហារីកដោះក្នុងចំណោមស្ត្រីអាស៊ី-អាមេរិកាំងបានកើនឡើង ក្រោយពីពួកគេបានចូលមករស់នៅក្នុងសហរដ្ឋអាមេរិក ។

នៅក្នុងចំណោមប្រជាជនទូទៅ ស្ត្រីម្នាក់ក្នុងចំណោមស្ត្រីពី ៨ទៅ១០នាក់ បានពិនិត្យឃើញមានកើតជម្ងឺមហារីកដោះក្នុងជីវិតរបស់គេ ។

សេចក្តីសង្ខេបនេះ នឹងជួយលោកអ្នកឲ្យយល់អំពីរោគវិនិច្ឆ័យ និងការជ្រើសរើសវិធីព្យាបាលជម្ងឺមហារីកដោះ ។



**ជម្ងឺមហារីក និងមូលហេតុរបស់វា**

រាងកាយមនុស្សបានកកើតឡើងដោយកោសិកាតូចៗ ។ កោសិកាក្នុងរាងកាយ ធម្មតា លូតលាស់ឡើង ហើយស្លាប់ទៅវិញតាមការកំណត់ ។ ជួនកាលកោសិកាទាំងនេះបំបែកចេញ ហើយលូតលាស់ឡើងខុសពីប្រក្រតី ដែលបណ្តាលឲ្យមានសាច់ដុះ ។

បើដុំសាច់ដុះនេះ មិនរាលដាលទៅកន្លែងផ្សេងទៀតនៃរាងកាយទេ គេហៅថាដុំសាច់ដុះមិនបណ្តាលឲ្យកើតជម្ងឺមហារីក ។ ដុំសាច់ដុះមិនមែន ជាមហារីកកម្រមានគ្រោះថ្នាក់ដល់ជីវិតមនុស្ស ណាស់ ។

បើដុំសាច់ដុះនោះ រាតត្បាតនិងបំផ្លាញកោសិកានៅជិតខាង យើងហៅថា ដុំសាច់មហារីក ។ មហារីក ជួនកាលអាចធ្វើឲ្យមនុស្សស្លាប់បាន ។

កោសិកាមហារីកទាំងនេះ អាចរាលដាលទៅកន្លែងដទៃនៃរាងកាយ តាមរយៈសសៃឈាម ឬច្រកលសិកា(ឬក៏ហៅថា ដុំទឹករងៃ)។

លសិកាគឺជាជាតិទឹកថ្លាៗ បង្កើតឡើងដោយរាងកាយ សំរាប់ចំរាញ់វត្ថុមិនស្អាតពីកោសិកា ហើយហូរកាត់តាមសសៃពិសេស មានទ្រង់ទ្រាយដូចគ្រាប់សណ្តែក ហៅថា ថ្នក់លសិកា ។

This document is a summary of what appears on screen in *X-Plain*. It is for informational purposes and is not intended to be a substitute for the advice of a doctor or healthcare professional or a recommendation for any particular treatment plan. Like any printed material, it may become out of date over time. It is important that you rely on the advice of a doctor or a healthcare professional for your specific condition.

©1995-2004, The Patient Education Institute, Inc. www.X-Plain.com oc1301c1

វិធីព្យាបាលជម្ងឺមហារីក គឺសំរាប់សម្លាប់ និងទប់ទល់នឹងកោសិកាមហារីក ដែលកើតឡើងខុសពីប្រក្រតី ។

ជម្ងឺមហារីកត្រូវបានឲ្យឈ្មោះតាមកន្លែងដែលមហារីកចាប់ផ្តើមកើតដំបូង ។ មហារីកដែលចាប់ផ្តើមនៅដោះ នឹងត្រូវបានហៅថា មហារីកដោះ ទោះបីជាវារាតត្បាតទៅកន្លែងផ្សេងដូចជា ថ្លើម ឆ្អឹង ឬ ខួរក្បាលក៏ដោយ ។

ថ្វីត្បិតតែគ្រូពេទ្យអាចរកឃើញកន្លែងដែលជម្ងឺមហារីកចាប់ផ្តើមកើតក៏ដោយ ជាទូទៅ យើងនៅតែមិនអាចសន្និដ្ឋានអំពីមូលហេតុដែលបណ្តាលឲ្យកើតមហារីកទេ ។

កោសិកាមានវត្ថុធាតុសំរាប់បន្តពូជ ។ វត្ថុធាតុនេះ សំរាប់គ្រប់គ្រងលើការលូតលាស់របស់កោសិកា ។

ជម្ងឺមហារីកតែងតែកើតឡើងដោយការផ្លាស់ប្តូរនៃវត្ថុធាតុសំរាប់បន្តពូជទាំងនេះ ។ នៅពេលវត្ថុធាតុសំរាប់បន្តពូជនៅក្នុងកោសិកាមួយ ប្រែប្រួលខុសពីប្រក្រតី នោះវានឹងបាត់បង់នូវលទ្ធភាពគ្រប់គ្រងលើការលូតលាស់របស់វា ។

ការផ្លាស់ប្តូរភ្លាមៗនូវវត្ថុធាតុបន្តពូជនេះ អាចកើតឡើងដោយមូលហេតុច្រើនយ៉ាង ។ ការផ្លាស់ប្តូរនេះ អាចបន្តមកពីឪពុកម្តាយ ឬកើតឡើងពីរោគឆ្លង ការប្រើគ្រឿងញៀន បារី ជាតិគីមី ឬកត្តាផ្សេងៗទៀត ។

ជម្ងឺមហារីកមិនមែនជាជម្ងឺឆ្លងទេ ។ អ្នកមានជម្ងឺនេះ មិនអាចចម្លងទៅឲ្យលោកអ្នកបានទេ ។ លោកអ្នកមិនអាចឈឺដោយសារតែបាននៅជិតអ្នកកើតជម្ងឺនេះ ឬបានប៉ះពាល់នឹងអាការៈនៃជម្ងឺនេះឡើយ ។

**ការវិភាគ អំពីដោះ**

ដោះមានជាលិកាដែលមានជាតិខ្លាញ់ និងក្រពេញផ្សេងៗ ។ ក្រពេញមានមុខងារចំពោះអ័រម៉ូនផ្សេងៗរបស់ស្ត្រី ដូចជាអេស្ត្រូចិន (estrogen) និងប្រូហ្សេសស្តេរ៉ូន (progesterone) ។ អ័រម៉ូនគឺជា វត្ថុធាតុក្នុងរាងកាយដែលជួយសំរួលដល់មុខងារផ្សេងៗរបស់រាងកាយ ។ អ័រម៉ូនរបស់ស្ត្រីជួយសំរួលដល់ការធ្លាក់រដូវ និងការមានផ្ទៃពោះ ។



ក្រពេញមានតួនាទីបង្កើតទឹកដោះ ក្រោយពេលដែលស្ត្រីបានសម្រាលកូនហើយ ។ ទឹកដោះត្រូវបានបញ្ចេញមកខាងក្រៅតាមបំពង់ពិសេស (ducts) ដែលចេញមកតាមចុងដោះ។

តាមធម្មតា ប្រព័ន្ធលសិកា បង្ហូរជាតិទឹកសំណល់របស់ដោះ ទៅក្នុងថ្នក់លសិកានៅក្នុងក្លៀក ហើយបន្ទាប់ពីនោះ ហូរត្រឡប់ទៅតាមប្រព័ន្ធឈាមវិញ ។ ដោះស្ថិតនៅលើសាច់ដុំសំខាន់ដែលធ្វើឲ្យដៃ និងសាច់ដុំផ្សេងៗ ដែលទាក់ទងនឹងការដកដង្ហើមមានចលនា ។

**ជម្ងឺមហារីកដោះ**

មហារីកដោះអាចមានដើមកំណើតពីក្រពេញ ឬពីបំពង់ទឹកដោះ (ducts)។



This document is a summary of what appears on screen in *X-Plain*. It is for informational purposes and is not intended to be a substitute for the advice of a doctor or healthcare professional or a recommendation for any particular treatment plan. Like any printed material, it may become out of date over time. It is important that you rely on the advice of a doctor or a healthcare professional for your specific condition.

©1995-2004, The Patient Education Institute, Inc. [www.X-Plain.com] oc1301c1

បើមហារីកមានប្រភពពីក្រពេញ គេហៅថា ឡូប្ូឡា កាស៊ីណូម៉ា (lobular carcinoma) ។ ឡូប្ូឡា ជាក្រពេញបង្កើតទឹកដោះ ។

បើមហារីកកើតឡើងនៅក្នុងបំពង់ទឹកដោះ គេហៅថា មហារីកបំពង់ទឹកដោះ (ductal carcinoma) ។

នៅពេលដែលមហារីករាលដាលផុតពីតំបន់ជុំវិញដោះ គេហៅថា មហារីកដែល "ជ្រៀតចូល" ឬ "រាលដាល" ។

កោសិកាមហារីកដែលពុំទាន់រាលដាលចេញក្រៅឡូប៉ូល (lobules) ឬបំពង់ (ducts) ហៅថា កាស៊ីណូម៉ា អិនស៊ីទូ (carcinoma insitu) ។

ជម្ងឺមហារីកដោះអាចកើតមានចំពោះមនុស្សជាច្រើននាក់ក្នុងគ្រួសារ ដែលតែងតែហៅថា មហារីកប្រចាំគ្រួសារ ។ ជម្ងឺមហារីកប្រភេទនេះ អាចកើតមានតាមពូជកំណើត ។ ថ្មីៗនេះ ការជឿនលឿនរបស់វេជ្ជសាស្រ្ត ស្តីពីពូជកំណើតបានធ្វើឲ្យគេស្គាល់នូវធាតុដើមរបស់ពូជ (gene) ខ្លះៗ ។ ស្រ្តីដែលមានជម្ងឺមហារីកដោះប្រចាំគ្រួសារ អាចទទួលការផ្តល់ឱវាទ និងការធ្វើតេស្តពិនិត្យមើលក្រែងមានជម្ងឺតាមពូជ ដើម្បីជាកិច្ចការពារ ។

មនុស្សមួយចំនួនមានជំនឿថា ស្រ្តីដែលមិនបំបៅដោះកូន ជាញឹកញាប់ អាចកើតជម្ងឺមហារីកដោះ ។ ទោះជាយ៉ាងណា ការបំបៅដោះកូនមិនអាចជំនួសការពិនិត្យដោះឲ្យបានទៀងទាត់នោះទេ ។ ស្រ្តីដែលបំបៅដោះកូនក៏អាចកើតជម្ងឺមហារីកដោះដែរ ។

**រោគសញ្ញា និងអាការៈរោគ**

ដំណាក់ការដំបូងនៃជម្ងឺមហារីក តាមធម្មតា មិនមានរោគសញ្ញាទេ ។ ក្រោយមក ពេលជម្ងឺមហារីកលូតលាស់ យើងអាចស្ទាបដឹងថា មានដុំសាច់ដុះនៅក្នុងដោះ ។

ជួនកាលស្បែកដែលគ្របលើដុំសាច់ដុះនោះ ក្លាយជាគគ្រើម ឬជ្រួញ ដែលមានលក្ខណៈដូចសំបកក្រូច ។ ការចេញវត្ថុធាតុរាវពីចុងដោះ អាចជាសញ្ញានៃជម្ងឺមហារីកដោះដែរ ។ ជម្ងឺមហារីកដោះ ភាគច្រើន ត្រូវបានរកឃើញដោយការពិនិត្យដោះដោយខ្លួនឯង ឬដោយការថតដោះ ។ ព្រោះតែមហារីកដោះខ្លះ អាចស្ទាបដឹងបានដោយមានដុំសាច់ដុះខុសពីធម្មតា ហើយខ្លះទៀតមិនអាចស្ទាបដឹងបាន ទើបធ្វើឲ្យការថតដោះមានសារៈសំខាន់ណាស់ ព្រោះអាចថតឃើញមហារីកដែលមិនអាចស្ទាបដឹង ។ ប៉ុន្តែ ការថតដោះដែលមានលទ្ធផលធម្មតា ក៏មិនបញ្ជាក់ថាមិនមានជម្ងឺមហារីកនោះទេ ។ បើអ្នកជម្ងឺ ឬគ្រូពេទ្យ ស្ទាបឃើញដុំសាច់ដុះនោះ យើងត្រូវតែពិនិត្យដោយវិធីច្រឹបសាច់យកមកពិនិត្យជម្ងឺ ហៅថា បាយយ៉ូបស៊ី (Biopsy) ។



**រោគវិនិច្ឆ័យ**

នៅពេលយើងរកឃើញជម្ងឺមហារីកដោះ គ្រូពេទ្យនឹងធ្វើការវះកាត់យកដុំមហារីកចេញ ដើម្បីធ្វើរោគ



This document is a summary of what appears on screen in *X-Plain*. It is for informational purposes and is not intended to be a substitute for the advice of a doctor or healthcare professional or a recommendation for any particular treatment plan. Like any printed material, it may become out of date over time. It is important that you rely on the advice of a doctor or a healthcare professional for your specific condition.

©1995-2004, The Patient Education Institute, Inc. [www.X-Plain.com] oc1301c1

វិនិច្ឆ័យបន្តទៀត ។ នៅពេលវះកាត់ គ្រូពេទ្យអាចពិនិត្យដុំលសិកានៅក្នុងក្លៀក ដើម្បីរកជម្ងឺមហារីក ។ អ្នកជំនាញនឹងយកដុំសាច់ដុះដែលបានកាត់ចេញ មកពិនិត្យ ដើម្បីវិនិច្ឆ័យថា ដុំសាច់ដុះនេះជាជម្ងឺមហារីក ឬមិនមែន ។

បើដុំសាច់ដុះនោះជាមហារីក នោះនឹងមានការធ្វើតេស្តពិនិត្យថែមទៀតដោយអ្នកជំនាញ ។ គ្រូពេទ្យវះកាត់ និងគ្រូពេទ្យជំនាញការខាងមហារីក អាចស្នើឲ្យលោកអ្នកធ្វើតេស្តដោយប្រើរស្មីបន្ថែមទៀត ។

ការធ្វើតេស្តខ្លះនឹងបង្ហាញឲ្យឃើញពីការលូតលាស់យ៉ាងឆាប់រហ័សនៃកោសិកាមហារីក ប្រៀបធៀបទៅនឹងកោសិកាធម្មតា ។ ជួនកាលអ័រម៉ូនស្ត្រី ដូចជា អេស្ត្រូចិន និងប្រូហ្សេសស្ទេរ៉ូន អាចប៉ះពាល់ដល់កោសិកាមហារីក ហើយមានតេស្តខ្លះឲ្យដឹងថា មានជម្ងឺកើតឡើង ។ ការធ្វើតេស្តទាំងនេះមានសារៈសំខាន់ក្នុងការជ្រើសយកវិធីព្យាបាលណាដែលប្រសើរជាងគេ ។

ការធ្វើតេស្តដោយប្រើរស្មីមានរួមទាំងការឆ្លុះមើលឆ្អឹង និងការថតឆ្លុះរបៀប **CAT** ស្កេន (CAT scan) ផ្សេងៗទៀត ដើម្បីមើលឲ្យដឹងថា តើជម្ងឺមហារីកនេះ រាតត្បាតចេញទៅក្រៅដោះ និងទៅតំបន់ក្លៀក ឬទេ ។

**ដំណាក់ការ**

ដំណាក់ការនិមួយៗ នឹងបង្ហាញនូវការលូតលាស់ និងការរាលដាលនៃជម្ងឺមហារីក ទៅផ្នែកផ្សេងៗក្នុងរាងកាយ ។ ការវះកាត់ គឺចាំបាច់ក្នុងការវិនិច្ឆ័យដំណាក់ការ និងប្រភេទមហារីក ដើម្បីឲ្យដឹងថា បើមហារីកបានរាលដាលទៅក្នុងលសិកា ។

ការឲ្យយោបល់ក្នុងការព្យាបាល យោងទៅលើដំណាក់ការនៃជម្ងឺមហារីក ។ យើងប្រើលេខពី ០ទៅ៤ ដើម្បីសំគាល់ដំណាក់ការរោគ ។ លេខទាបមានន័យថា ៖ ជាដំណាក់ការដំបូងរបស់ជម្ងឺមហារីក ។

ដំណាក់ការខ្លះត្រូវបានចែកជាដំណាក់ការតូចៗ ថែមទៀត ។ ដំណាក់ការតូចៗ ទាំងនោះតម្រូវឲ្យមានជាអក្សរមួយ ។ ឧទាហរណ៍ ដំណាក់ការ ៣អេ (A) និងដំណាក់ការ ៣បី (B) ។ ដំណាក់ការ ៣បី ធ្ងន់ធ្ងរជាងដំណាក់ការ ៣អេ ។ ដំណាក់ការ "០" នៃជម្ងឺមហារីកដោះ មិនទាន់រាលដាលពីបំពង់ដាកត៏ (duct) ទៅឡូប៊ូល ហៅថា កាស៊ីណូម៉ា អ៊ិនស៊ីទូ (carcinoma in-situ) ។ នៅពេលដែលជម្ងឺមហារីកផ្តើមកើតពីឡូប៊ូល គេហៅថា មហារីកឡូប៊ូឡា (lobular carcinoma) ។ បើជម្ងឺមហារីកកើតពីបំពង់ទឹកដោះ គេហៅថា មហារីកបំពង់ទឹកដោះ (ductal carcinoma) ។ មហារីកបំពង់ទឹកដោះ ភាគច្រើន អាចរកឃើញនៅដំណាក់ការលេខ "០" ។ បច្ចុប្បន្ននេះ ការថតដោះអាចរកឃើញជម្ងឺមហារីកបំពង់ទឹកដោះពី ៣០ទៅ៤០ ភាគរយ ។

ដំណាក់ការទី១ ជម្ងឺមហារីកដោះមានទំហំតូចជាង ២ សង្ទីម៉ែត្រ ហើយមិនទាន់រាលដាលទៅក្រៅដោះទេ ។

ដំណាក់ការទី២ ជម្ងឺមហារីកដោះអាចមានលក្ខណៈមួយដូចខាងក្រោមនេះ :



This document is a summary of what appears on screen in *X-Plain*. It is for informational purposes and is not intended to be a substitute for the advice of a doctor or healthcare professional or a recommendation for any particular treatment plan. Like any printed material, it may become out of date over time. It is important that you rely on the advice of a doctor or a healthcare professional for your specific condition.

©1995-2004, The Patient Education Institute, Inc. [www.X-Plain.com] oc1301c1

❖ ទំហំតូចជាង ២សង្ទីម៉ែត្រ ប៉ុន្តែមានលសិកាពីរ ឬបីនៅក្លៀកដែរ ។
❖ ទំហំ ២ទៅ៥ សង្ទីម៉ែត្រ ប៉ុន្តែមិនមានលសិកានៅក្លៀកទេ ។

ដំណាក់ការទី ៣អេ ជម្ងឺមហារីកដោះអាចមានលក្ខណៈមួយដូចខាងក្រោមនេះ :
❖ មានទំហំតូចជាង ៥ សង្ទីម៉ែត្រ ហើយបានរាលដាលចូលជ្រៅទៅក្នុងលសិកា ដែលនៅក្នុងក្លៀក ។
❖ មានទំហំ ៥ សង្ទីម៉ែត្រ ឬធំជាង គ្រាន់តែរាលដាលទៅដល់លសិកាក្នុងក្លៀក ។

ដំណាក់ការទី ៣បី ជម្ងឺមហារីកដោះអាចមានលក្ខណៈមួយដូចខាងក្រោមនេះ :
❖ ជម្ងឺមហារីកមាននៅលើស្បែក និងសន្ទះទ្រូង ។
❖ ជម្ងឺមហារីករាលដាលដល់លសិកា តាមបណ្ដោយផ្ទៃខាងក្នុង និងតាមឆ្អឹងដោះ ។
❖ ជម្ងឺមហារីករាលដាលទៅលសិកាដទៃទៀត ដែលនៅជិតដោះ នៅជុំវិញឆ្អឹងដងកាំបិត ឬខាងក្រោមក ។

ដំណាក់ការទី៤ មហារីកដោះបានរាលដាលទៅដល់សរីរាង្គដទៃទៀត ដូចជា ឆ្អឹង ថ្លើម និងខួរក្បាល ។

**ការវះកាត់**

ភាគច្រើន ជម្ងឺមហារីកដោះត្រូវបានវះកាត់យកចេញ ។ ពេលវេលាសំរាប់ការវះកាត់ អាស្រ័យលើទំហំ កន្លែងដែលកើតជម្ងឺមហារីក និងករណីដែលមានលសិកានៅក្នុងក្លៀកទាក់ទង ឬមិនទាក់ទង ។



វិធីវះកាត់ជម្ងឺមហារីកដោះមានគោលដៅពីរ ។ ទីមួយ គឺកាត់យកដុំមហារីកចេញទាំងអស់ មិនបន្សល់ទុកនូវកោសិកាមហារីកឲ្យនៅក្នុងដោះឡើយ ។

គោលដៅទីពីរ គឺពិនិត្យថ្នក់លសិកានៅក្លៀក ដើម្បីឲ្យដឹងប្រាកដថា មិនមានមហារីករាលដាលដល់ទីនោះទេ ។ បើមានមហារីករាលដាលដល់ទី នោះគ្រូពេទ្យអាចសន្និដ្ឋានចំនួនថ្នក់លសិកាដែលទាក់ទងនឹងដុំសាច់ដុះនោះ ។

ដោយហេតុថាការវះកាត់យកថ្នក់លសិកាចេញច្រើនអាចបណ្ដាលឲ្យហើមដៃហៅថា ជម្ងឺហើម ។ បច្ចេកទេសថ្មីកំពុងបានបង្កើត ដើម្បីវះកាត់យកតែលសិកាណាដែលសំខាន់ៗចេញ ។

ពីរ ឬបីម៉ោងមុនពេលវះកាត់ គ្រូពេទ្យនឹងចាក់ថ្នាំជុំវិញកន្លែងដុំសាច់មហារីក ដោយប្រើលាក់ពិសេសម្យ៉ាង ពណ៌ខៀវ ឬវិទ្យុសកម្មថ្នាំជ្រលក់ពណ៌ ដែលមិនមានគ្រោះថ្នាក់ ដើម្បីឲ្យដឹងពីភាពខុសគ្នារបស់ជាលិកា។

នៅពេលវះកាត់ គ្រូពេទ្យវះយកដុំមហារីកចេញ ហើយអាចឃើញ លសិកាដែលបានបញ្ចូលថ្នាំពណ៌នោះ ។ លសិកាទីមួយ ដែលទទួលជាតិថ្នាំនោះ ហៅថា លសិកាសង្ទីណែល (sentinel node) ។

វិធីវះកាត់យកដុំសាច់ដុះ សំដៅទៅលើការកាត់



This document is a summary of what appears on screen in *X-Plain*. It is for informational purposes and is not intended to be a substitute for the advice of a doctor or healthcare professional or a recommendation for any particular treatment plan. Like any printed material, it may become out of date over time. It is important that you rely on the advice of a doctor or a healthcare professional for your specific condition.

©1995-2004, The Patient Education Institute, Inc. [www.X-Plain.com] oc1301c1

យកដុំមហារីកចេញ ដោយមានការច្រឹបយកលសិកានៅក្នុងក្លៀក ហៅថា បាយយ៉ូបស៊ី (biopsy) ។ ឡាំប៉ិកតូមី គឺជាវិធីវះកាត់មួយប្រើសំរាប់វះកាត់យកមហារីកដោះចេញ ដែលកំពុងពេញនិយមសព្វថ្ងៃនេះ ។ តាមធម្មតា វិធីព្យាបាលដោយកម្មរស្មីត្រូវបានប្រើក្រោយវិធីវះកាត់រួច ។

ការវះកាត់ដោះបែបម៉ាស់ស្ទិកតូមី (ការកាត់យកចេញខ្លះ) គឺត្រូវកាត់យកសាច់ដោះមួយចំណែកធំចេញ ច្រើនជាងការវះកាត់បែបឡាំពិកតូមី ។ ស្រទាប់សាច់ដុំភាគខាងក្រោមដោះ ក៏អាចត្រូវវះយកចេញដែរ ។ ក្រោយពីវះយកថ្នក់លសិកាចេញ ការព្យាបាលដោយប្រើកាំរស្មីត្រូវតែធ្វើ ដើម្បីឲ្យដឹងថា តើមហារីកមានបានរាលដាល ឬទេ ។

វិធីវះកាត់ដោះបែបម៉ាស់ស្ទិកតូមី (ការកាត់យកចេញទាំងអស់) គឺវះយកដោះទាំងមូលចេញ ជាមួយនឹងថ្នក់លសិកាមួយចំនួននៅក្លៀក ។

វិធីវះកាត់ដោះបែប រ៉ាឌីកាល់ ម៉ាស់ស្ទិកតូមី គឺវះយកដោះចេញ ស្រទាប់ដែលគ្របសាច់ដុំ ឬជួនកាលអាចកាត់យកសាច់ដុំចេញខ្លះផង ។ ការវះកាត់ប្រភេទនេះ ក៏បានវះយកថ្នក់លសិកាមួយចំនួននៅក្លៀកចេញដែរ ។

វិធីវះកាត់បែប រ៉ាឌីកាល់ ម៉ាស់ស្ទិកតូមី គឺសំរាប់វះកាត់យកដោះចេញ សាច់ដុំដែលនៅខាងក្រោមដោះ និងថ្នក់លសិកាទាំងអស់នៅក្នុងដោះនោះ ។ ជាច្រើនឆ្នាំមកនេះ យើងបានគិតថា ការវះកាត់នេះ ជាវិធីដ៏ប្រសើរបំផុត ។ ក៏ប៉ុន្តែនៅពេលថ្មីៗនេះ យើងពុំសូវបានយកមកប្រើការទេ ។

**ការព្យាបាលបន្ថែម**

ក្រោយពេលវះកាត់រួច គ្រូពេទ្យរបស់លោកអ្នកអាចសុំឲ្យលោកអ្នកធ្វើការព្យាបាលបន្ថែមខ្លះទៀត ដើម្បីការពារកុំឲ្យមហារីកកើតឡើងវិញ ។ ការព្យាបាលបន្ថែមមាន ការព្យាបាលដោយប្រើកម្មរស្មី (radiation ) និងប្រើគីម៉ូតេរ៉ាពី ។

វិធីព្យាបាលដោយកម្មរស្មី គឺជាលំដាប់ព្យាបាលដោយប្រើកម្មរស្មីអ៊ិក្ស ដើម្បីបំផ្លាញកោសិកាមហារីក ដែលមាននៅក្នុងថ្នក់លសិកា ឬក្នុងដោះ ។ តាមធម្មតា ត្រូវចំណាយពេលពី ៥ទៅ៦ អាទិត្យទើបបញ្ចប់ការព្យាបាលនេះបាន ។

តាមធម្មតា វិធីព្យាបាលដោយកម្មរស្មីត្រូវបានប្រើ :

- ក្រោយពេលវះយកដុំសាច់ដុះចេញ
- ក្រោយពេលវះកាត់ដោះ បើដុំមហារីកមានទំហំធំជាង ៥សង្ទីម៉ែត្រ
- បើយើងរកឃើញថ្នក់លសិកាជាច្រើនពាក់ពាន់នឹងមហារីកនោះ
- បើដុំមហារីកស្ថិជាប់នឹងសាច់ដុំនៃជញ្ជាំងទ្រូង ឬជាប់នឹងឆ្អឹងជំនី ។

ក្រោយពេលវះកាត់ ពេទ្យអាចស្នើឲ្យប្រើជាតិអ័រម៉ូន និងគីម៉ូតេរ៉ាពី ជាថ្នាំព្យាបាលដើម្បីការពារកុំឲ្យមហារីកកើតឡើងវិញបាន ។ អ្នកជម្ងឺអាចប្រើថ្នាំលេប ឬចាក់តាមសសៃឈាម ។

ការព្យាបាលដោយប្រើជាតិអ័រម៉ូនត្រូវបានអនុវត្តបើគេរកឃើញថាមាន ធាតុបំប៉នអេស្ត្រូចិន និងប្រូហេស្សេរ៉ូន ។ ជាទូទៅ ធាតុបំប៉នទាំងនោះ



This document is a summary of what appears on screen in *X-Plain*. It is for informational purposes and is not intended to be a substitute for the advice of a doctor or healthcare professional or a recommendation for any particular treatment plan. Like any printed material, it may become out of date over time. It is important that you rely on the advice of a doctor or a healthcare professional for your specific condition.

©1995-2004, The Patient Education Institute, Inc. [www.X-Plain.com] oc1301c1

គឺជួយបង្កើនឲ្យជម្ងឺមហារីកលូតលាស់កាន់តែលឿន ។

ការព្យាបាលដោយប្រើអ័រម៉ូន និងថ្នាំតាម៉ូស៊ីហ្វិន ឬថ្នាំប្រហាក់ប្រហែលផ្សេងទៀត អាចទប់ស្កាត់ឥទ្ធិពលរបស់ជាតិអេស្ត្រូចិន និងប្រូហេស្រសស្តេរ៉ូន ។ គ្រូពេទ្យអាចណែនាំស្ត្រី មួយចំនួន នៅពេលដែលស្ត្រីជិតអស់រដូវ គួរវះកាត់យកដៃស្បូនចេញ ដើម្បីបញ្ឈប់ការបង្កើតជាតិអេស្ត្រូចិន និងប្រូហេស្រសស្តេរ៉ូន ក្រោយពេលដែលបានវះកាត់យកមហារីកដោះចេញរួចហើយ ។

វិធីព្យាបាលបែបគីម៉ូតេរ៉ាពី តាមធម្មតា ត្រូវបានអនុវត្តក្នុងករណីដែលមហារីកដោះមានទំហំធំ ហើយរាលដាលទៅដល់លសិកា ក្រពេញ ឬដល់សរីរាង្គផ្សេងទៀតក្នុងរាងកាយ ។ ជួនកាលត្រូវព្យាបាលដោយរបៀបគីម៉ូតេរ៉ាពី ដើម្បីជួយបន្ថយគ្រោះថ្នាក់កុំឲ្យជម្ងឺរើឡើងវិញ ទោះបីជម្ងឺមិនរាលដាលចេញក្រៅដោះក៏ដោយ ។

យើងអាចប្រើវិធីព្យាបាលបែបគីម៉ូតេរ៉ាពី សំរាប់ស្ថានភាពខុសៗគ្នាជាច្រើន ។ គ្រូពេទ្យឯកទេសខាងជម្ងឺមហារីក អាចពិគ្រោះជាមួយលោកអ្នកនូវអ្វីដែលគាត់គិតថា ជាការជ្រើសយកវិធីព្យាបាលដ៏សមគួរសំរាប់លោកអ្នក ។

ធ្វើការពិសោធន៍ព្យាបាលក៏ជារបៀបជ្រើសរើសមួយក្នុងការព្យាបាល ។ នេះជាបទពិសោធន៍មួយបែបដើម្បីស្វែងរកវិធីព្យាបាលថ្មី ។ ការពិសោធន៍នេះត្រូវបានយល់ថា យ៉ាងហោចណាស់ ក៏ជាវិធីព្យាបាលមានប្រសិទ្ធិភាពក្នុងបច្ចុប្បន្ននេះដែរ ។ វិធីព្យាបាលនេះ ត្រូវបានស្នើជំនួសកិច្ចព្យាបាលមួយចំនួនដូចបានពោលខាងលើ ។ យូរៗម្តង នៅមន្ទីរពេទ្យ អ្នកជម្ងឺអាចមានឱកាសចូលរួមក្នុងការពិសោធន៍ព្យាបាលនេះ ហើយគេក៏មានសិទ្ធិជ្រើសរើសចូលរួម ឬមិនចូលរួម ។

វិធីព្យាបាលដោយធ្វើការពិសោធន៍ ត្រូវបានពិនិត្យឡើងវិញដោយមន្ទីរពេទ្យ វេជ្ជបណ្ឌិត និងដោយអ្នកផ្តល់ឱវាទនៅក្នុងសហគមន៍ ។ ការពិសោធន៍ព្យាបាលត្រូវតែមានសុវត្ថិភាព និងផ្តល់កិច្ចព្យាបាលដែលគេយល់ថា មានប្រសិទ្ធិភាពដ៏ប្រសើរ ។ (ការពិសោធន៍ខ្លះ ផ្តល់របៀបព្យាបាលថ្មីបំផុតឲ្យអ្នកជម្ងឺជំនួសកិច្ចព្យាបាលធម្មតា ។ ការពិសោធន៍ព្យាបាលខ្លះទៀត អ្នកជម្ងឺត្រូវព្យាបាល តាមរបៀបថ្មី ឬធម្មតា ហើយអ្នកជម្ងឺមិនអាចជ្រើសរើសវិធីព្យាបាលបានឡើយ) ។



## ក្រោយពេលធ្វើរោគវិនិច្ឆ័យ

ក្រោយពេលធ្វើរោគវិនិច្ឆ័យរួច ភាគច្រើន អ្នកជម្ងឺមានការបារម្ភអំពីលទ្ធផល និងប្រសិទ្ធិភាពនៃការព្យាបាល ដូចជាការវះកាត់ និងការព្យាបាលដោយប្រើគីម៉ូតេរ៉ាពី ។ ជាសំណាងល្អណាស់ ដែមានរបៀបខ្លះ អាចជួយធ្វើឲ្យអ្នកជម្ងឺមានអារម្មណ៍ល្អ ។

ការវះកាត់កែសម្ផស្ស នឹងប្រើគ្រឿងសិប្បនិមិត្ត (ដូចជា ជើង ឬសរីរាង្គផ្សេងៗ ដែលធ្វើរពីជ័រ



This document is a summary of what appears on screen in *X-Plain*. It is for informational purposes and is not intended to be a substitute for the advice of a doctor or healthcare professional or a recommendation for any particular treatment plan. Like any printed material, it may become out of date over time. It is important that you rely on the advice of a doctor or a healthcare professional for your specific condition.

©1995-2004, The Patient Education Institute, Inc. [www.X-Plain.com] oc1301c1

ឬដែក) ដែលអាចជួយកែប្រែរូបសម្ផស្សអ្នកជម្ងឺ ដោយធ្វើមិនឲ្យអ្នកដ៏ទៃមើលដឹងថា មានការវះកាត់ ឬមិនមាន ។

ក្នុងករណីខ្លះ ការព្យាបាលដោយរបៀបតឹម្ង៉ូតេរ៉ាពីអាចនាំឲ្យជ្រុះសក់ជាបណ្តោះអាសន្ន ។ ដូច្នេះ លោកអ្នកគួររកសក់ក្លែងក្លាយប្រុងប្រៀបទុកជាមុន ។

មានក្រុមឧបត្ថម្ភអ្នកជម្ងឺ និងបណ្តាញរបស់គេខ្លះធ្លាប់មានបទពិសោធន៍ប្រហាក់ប្រហែលអ្នកជម្ងឺដែរ ។ ក្នុងក្រុមនោះ មានអ្នកខ្លះធ្លាប់កើតជម្ងឺមហារីកដោយខ្លួនឯងផ្ទាល់ ហើយក៏បានគេចផុតពីសេចក្តីស្លាប់ដោយសារជម្ងឺនោះដែរ ។ ហើយគេក៏ពេញចិត្តនឹងនិយាយប្រាប់នូវបទពិសោធន៍ ដែលគេធ្លាប់ជួបប្រទះ ។ ការចូលរួមជាមួយក្រុមឧបត្ថម្ភអ្នកជម្ងឺនេះ ឬជួបជាមួយអ្នកដែលយល់ពីអារម្មណ៍របស់លោកអ្នក ជួនកាលអាចជាជំនួយដ៏ល្អក្នុងការជួយលោកអ្នកឲ្យឆាប់បានសះស្បើយពីជម្ងឺផង ។

ការព្យាបាលជម្ងឺមហារីកអាចបណ្តាលឲ្យមានការក្អួតចង្អោរ និងនឿយហត់ ក៏ប៉ុន្តែមានវិធីផ្សេងៗ ដើម្បីកាត់បន្ថយប្រតិកម្មថ្នាំទាំងនេះ និងជួយសម្រួលអារម្មណ៍អ្នកជម្ងឺឲ្យបានប្រសើរឡើងវិញ ។

## សេចក្តីសរុប

ជម្ងឺមហារីកដោះជាជម្ងឺមួយដែលកើតឡើងច្រើនជាងគេ ក្នុងចំណោមជម្ងឺមហារីកផ្សេងៗ ។ អ្នកខ្លះជឿថា ស្ត្រីដែលមិនសូវបំបៅដោះកូន តែងតែកើតជម្ងឺមហារីកដោះ ។ ទោះជាយ៉ាងណា ស្ត្រីយើងមិនអាចយកការបំបៅដោះកូនមកជំនួសការពិនិត្យដោះឲ្យបានទៀងទាត់នោះទេ ។ ស្ត្រីដែលបំបៅដោះកូនក៏អាចកើតជម្ងឺមហារីកដោះដែរ ។

ការឆាប់រកឃើញជម្ងឺបន្ថែមនូវជោគជ័យក្នុងការព្យាបាល ។ ជាការសំខាន់ណាស់ដែលស្ត្រីត្រូវតែពិនិត្យដោះដោយខ្លួនឯង និងធ្វើការណាត់ថតដោះឲ្យបានទៀងទាត់ ។

សព្វថ្ងៃនេះ ស្ត្រីអាចជ្រើសរើសការព្យាបាលវះកាត់កែសម្រួលដោះ ។

សភាពរបស់ស្ត្រីដែលមានជម្ងឺមហារីកដោះឥឡូវនេះ មានភាពប្រសើរជាងពីមុន ។



This document is a summary of what appears on screen in *X-Plain*. It is for informational purposes and is not intended to be a substitute for the advice of a doctor or healthcare professional or a recommendation for any particular treatment plan. Like any printed material, it may become out of date over time. It is important that you rely on the advice of a doctor or a healthcare professional for your specific condition.

©1995-2004, The Patient Education Institute, Inc. [www.X-Plain.com] oc1301c1